ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**
លេខ ១២៩ “ឥ១” ក្រ៨
ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០២៣
**សំណុំរឿងព្រហ្មទណ្ឌ**
លេខ ១៣០៨
ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២
**សំណុំរឿងស៊ើបសួរ**
លេខ ១០៦៣
ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២
**ជំនុំជម្រះ**
លេខ ៣៩៨០
ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២

**នាមនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈនាថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣

វេលាម៉ោង ២ និង ៣០ នាទី រសៀល សាលសវនាការទី២ ជាន់ទី១

ដោយមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted]ក្រុមប្រឹក្សាជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ
លោក [redacted]ៅក្រមប្រឹក្សានៃសាលាដំបូងរាជធានីភ្នំពេញ
លោក [redacted] ចៅក្រមប្រឹក្សានៃសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted]ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៣៦៨ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖**

១-ឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅសង្កាត់[redacted]ខណ្ឌពោធិ៍សែនជ័យ? ការពិត កណ្តាល បច្ចុប្បន្ននៅមណ្ឌលអប់រំកែប្រែទី១ “ម១” ឪពុកឈ្មោះ [redacted] **វុទ្ធី** “រស់” ម្តាយឈ្មោះ [redacted] **ឃឿន** “រស់” ប្រពន្ធឈ្មោះ [redacted] **សុគន្ធារី** មានកូនចំនួន ០១ នាក់ ជាតិជន ទោសពីមុខគ្មាន ។ (ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៩៥០ “ខ” ដ.ឃ.ដ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ នៅមណ្ឌលអប់រំកែប្រែទី១ “ម១”)

២-ឈ្មោះ [redacted] **ម៉េងគង់** ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកំពង់ចាម ទីលំនៅមុនពេលឃុំខ្លួននៅ បុរីចំការដូង ផ្ទះលេខF៣០ ផ្លូវបេតុង សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] **តារាវុធ** “ស្លាប់” ម្តាយឈ្មោះ [redacted] **ធារី** “រស់” នៅលីវ ជាតិជន ទោសពីមុខមាន (កាលឆ្នាំ២០២០ ធ្លាប់ជាប់ពន្ធនាគារ ខេត្តត្បូងឃ្មុំរយៈពេល ០១ឆ្នាំ ពីបទ រំលោភលើទំនុកចិត្ត) ។ (ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៣២៦ “ខ” ដ.ឃ.ដ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ នៅមណ្ឌលអប់រំកែប្រែទី១ “ម១”)

៣-ឈ្មោះ [redacted] **គេងហួរសុដារី** ភេទស្រី អាយុ ២០ឆ្នាំ ជនជាតិខ្មែរ មុខរបររៀនសំអាង ទីកន្លែងកំណើត[redacted]ខេត្តកំពង់ចាម ទីលំនៅមុនពេលឃុំខ្លួននៅ បុរីចំការដូង ផ្ទះលេខF៣០ ផ្លូវបេតុង សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] **គេងហួរ** “រស់” ម្តាយឈ្មោះ [redacted] **ដារាម**

"រស់" នៅលើរ ជាទីតិជន ទោសពីមុនគ្មាន ។ (ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៣២៧ "ម" ជ.ឃ.ង ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ នៅ ពន្ធនាគាររាជធានីភ្នំពេញ "PJ")

ជាប់ចោទពីបទ **ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចបុរីចំការដូងផ្ទះលេខF៣០ ផ្លូវបេតុង សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ និងខេត្តពោធិ៍សាត់ កាលពីអំឡុងខែមីនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២២ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ និងថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤-ឈ្មោះ [redacted] **សុគន្ធារី** ភេទស្រី អាយុ ៣៧ឆ្នាំ ជនជាតិខ្មែរ មុខរបរជាងអ៊ុតសក់ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល ទីលំនៅមុនពេលឃុំខ្លួននៅផ្ទះលេខ៥៩៤ ក្រុមទី១៧ ក្រុមទី១៧ ភូមិព្រែកកាំង១ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] **សុផាត** "រស់" ម្តាយឈ្មោះ [redacted] **សុភារី** "ស្លាប់" ប្តីឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** មានកូនចំនួន ០១ នាក់ ជាទីតិជន ទោសពីមុនគ្មាន ។ (ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៣២៥ "ខ" ជ.ឃ.ង ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ នៅមណ្ឌលអប់រំកែប្រែទី២ "ម២")

ជាប់ចោទពីបទ **កាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** ប្រព្រឹត្តនៅចំណុច តាខ្មៅ ផ្ទះលេខ៥៩៤ ក្រុមទី១៧ ភូមិព្រែកកាំង សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ ។

លោកមេធាវី [redacted] មានការិយាល័យនៅផ្ទះលេខ២៨ ផ្លូវ៤០៨ ក្រុម២៤ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សុគន្ធារី** និងឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** ។

លោកមេធាវី [redacted] មានការិយាល័យនៅផ្ទះលេខ២៨ ផ្លូវ៤០៨ ក្រុម២៤ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សុគន្ធារី** ។

លោកមេធាវី [redacted] មានការិយាល័យនៅកោះពេជ្រអគារ ជីអាយ អេ (GIA Tower) ជាន់ទី២៣ ផ្លូវសុភមង្គល សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** ។

លោកមេធាវី [redacted] មេធាវីក្រុមមេធាវី គជសីហ៍ ការិយាល័យនៅផ្ទះលេខ២៨ ផ្លូវ៤០៨ ក្រុម២៤ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ម៉េងគង់** និងឈ្មោះ [redacted] **អេងហួរសុដារី** ។

លោកមេធាវី [redacted] ជាមេធាវីការពារក្តីជូនជនក្រីក្រដោយឥតគិតកម្រៃ (លិខិតចាត់តាំងលេខ ៨៩៥/ប្រ.គម/ភព/២២ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា) ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** ឈ្មោះ [redacted] **ម៉េងគង់** និងឈ្មោះ [redacted] **អេងហួរសុដារី** ។

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ១៧ និង ២០ នាទី មន្ត្រីប្រឆាំងគ្រឿងញៀន នៃក្រសួងមហាផ្ទៃ បានចុះបង្ក្រាបករណី ដឹកជញ្ជូន រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងរក្សាទុកអាវុធដោយខុសច្បាប់ នៅចំណុចបុរីចំការដូង ផ្ទះលេខF៣០ ផ្លូវបេតុង សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ បង្ករឡើងដោយឈ្មោះ [redacted] **ម៉េងគង់** និងឈ្មោះ [redacted] **អេងហួរសុដារី** ដោយបានដកហូតវត្ថុតាងក្រោមពណ៌សថ្លា ប្រភេទហេរ៉ូអ៊ីន និងមេតំហ្វេតាមីន ទម្ងន់ ២១.១៧៥,០៩ ក្រាម (២១ គីឡូ និង ១៧៥,០៩ ក្រាម) នៅក្នុងបុរីចំការដូង ផ្ទះលេខF៣០

ផ្លូវបេតុង សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ រួចបន្តឈានទៅដល់ការឆែកឆេរផ្ទះរបស់ឈ្មោះ [redacted] **សុគន្ធារី** ស្ថិតនៅផ្ទះលេខ៥៨៤ ក្រុមទី១៧ ភូមិព្រែករាំង១ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល រកឃើញអាវុធខ្លីមួយដើមម៉ាក G LOCK ១៩ មានលេខ YC209356 បង់ចំនួន ០១ បង់ និងគ្រាប់ចំនួន ០៣ គ្រាប់ យកមកធ្វើការសាកសួរ តែម្តង ។ ក្រោយពីការសាកសួរឈ្មោះ [redacted] **ម៉េងគង់** បានឆ្លើយសារភាពថា ខ្លួនធ្លាប់ធ្វើសកម្មភាពជួញដូរគ្រឿងញៀនតាំងពីថ្ងៃមិនចាំ ខែមីនា ឆ្នាំ២០២០ មក ដោយបានទិញថ្នាំញៀនពីឈ្មោះ **យួន** ។ ពេលទិញម្តង១ក្នុងតម្លៃ ៣០០.០០០ រៀល (សាមសិបម៉ឺនរៀល) យកទៅរំលែកលក់បានតម្លៃ ៦០០.០០០ រៀល (ហុកសិបម៉ឺនរៀល) លុះដល់ថ្ងៃមិនចាំ ខែមករា ឆ្នាំ២០២២ ឈ្មោះ **យួន** បានណែនាំឈ្មោះ [redacted] **ម៉េងគង់** ឱ្យស្គាល់ឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** ហៅ **ផាន់ណា** កំពុងឃុំខ្លួននៅពន្ធនាគារព្រៃស តាមគណនីហ្វេសប៊ុកឈ្មោះ "ស្រលាញ់ស្នេហ៍" ក្រោយពីឈ្មោះ [redacted] **ម៉េងគង់** បានទំនាក់ទំនងជាមួយឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** តាមរយៈឆាតមក នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២ ឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** បានប្រើឱ្យជនសង្ស័យឈ្មោះ [redacted] **ម៉េងគង់** ឡើងទៅខេត្តកំពង់ឆ្នាំង ដើម្បីយកគ្រឿងញៀនពីមនុស្សម្នាក់មិនស្គាល់ឈ្មោះ ដោយប្រើលេខទូរស័ព្ទ ០៩៧ ៩៧៦ ៧២៤៥ ដោយបានជិះទៅម្តងឯង ក្រោយមកនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ ឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** បានឆាតឱ្យទៅ នៅមុំតំបន់សេដ្ឋកិច្ចពិសេសនៅកំបូលដើម្បីយករថយន្ត និងកាំភ្លើងពីឈ្មោះ **ម៉ៅ** ភេទប្រុស អាយុប្រហែល៣២ឆ្នាំ ប្រើប្រាស់ទូរស័ព្ទលេខ ០១០ ៧០៥៧៥៨ ពេលទៅដល់ ឈ្មោះ [redacted] **ម៉េងគង់** ក៏ទទួលរថយន្តម៉ាកព្រូស ពណ៌ស ពាក់ស្លាកលេខភ្នំពេញ ២AX-០៣៣១ និងកាំភ្លើងម៉ាក G LOCK ១៩ ចំនួន ០១ ដើម ពីឈ្មោះ **ម៉ៅ** ហើយក៏មិនបានសួរថា កាំភ្លើងរបស់នរណានោះដែរ ហើយក៏បានត្រលប់ទៅផ្ទះជួលនៅបុរីចិការដូង ស្ថិតនៅផ្ទះលេខF៣០ ផ្លូវបេតុង សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ ផ្ទះជួលនេះទើបតែជួលបានមួយថ្ងៃប៉ុណ្ណោះ ក្រោយមកក៏បានជិះម៉ូតូកង់បីទៅទទួលសង្សារឈ្មោះ [redacted] **អេងហួរសុដារី** នៅក្រុងតាខ្មៅ ជាផ្ទះរបស់ឈ្មោះ [redacted] **សុគន្ធារី** ដែលជាត្រូវជាប្រពន្ធរបស់ឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** ។ លុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ ឈ្មោះ [redacted] **ម៉េងគង់** និងឈ្មោះ **ដេវីត** ភេទប្រុស អាយុប្រហែល ២៣ ឆ្នាំ ប្រើប្រាស់ទូរស័ព្ទលេខ ០៨៧ ៤២៤៤៤១ បានធ្វើដំណើរទៅខេត្តពោធិ៍សាត់ដោយជិះរថយន្តម៉ាកព្រូស និងយកកាំភ្លើងខាងលើទៅតាមខ្លួនដើម្បីទៅយកថ្នាំញៀនតាមការណែនាំរបស់ឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** ដោយឱ្យទំនាក់ទំនងទៅបុរសម្នាក់មិនស្គាល់ឈ្មោះ ប្រើប្រាស់ទូរស័ព្ទលេខ ០៩៧ ៩៧៦៧២៤៥ ពេលទំនាក់ទំនងទៅក៏បានយកគ្រឿងញៀនមួយចំនួនធំក្រុកក្នុងបាវ រួចក៏បានត្រឡប់មកភ្នំពេញវិញជាមួយឈ្មោះ **ដេវីត** ហើយឈ្មោះ [redacted] **ម៉េងគង់** ក៏បានយកថ្នាំញៀនទៅទុកក្នុងផ្ទះជួលរបស់ឈ្មោះ [redacted] **ម៉េងគង់** ខាងលើនៅចិការដូង ថ្ងៃខែឆ្នាំដដែល ។ ឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** បានឆាតមកឈ្មោះ [redacted] **ម៉េងគង់** ឱ្យយកកាំភ្លើងខាងលើនេះទៅប្រគល់ឱ្យប្រពន្ធរបស់ឈ្មោះ [redacted] **ឡេង ប៊ុនរ៉ា** និងប្រគល់បន្តឱ្យឈ្មោះ [redacted] **សុគន្ធារី** ដែលមានផ្ទះលេខ៥៨៤ ក្រុមទី១៧ ភូមិព្រែករាំង សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល ក្រោយពេលប្រគល់កាំភ្លើងឱ្យទៅឈ្មោះ [redacted] **សុគន្ធារី** រួចឈ្មោះ [redacted] **ម៉េងគង់** និងសង្សារឈ្មោះ [redacted] **អេងហួរសុដារី** ក៏បានត្រលប់ទៅផ្ទះជួលវិញ ។ ឈ្មោះ [redacted] **ម៉េងគង់** ក៏បានយករថយន្តទៅលាង ពេលត្រលប់មកវិញមិនទាន់បានចូលផ្ទះផង ក៏ស្រាប់តែមានសមត្ថកិច្ចមួយក្រុមបានចាប់ឃាត់ខ្លួនរូបខ្លួន ដោយប្រាប់ថាពាក់ព័ន្ធគ្រឿងញៀន និងចូលធ្វើការឆែកឆេរផ្ទះរកឃើញគ្រឿងញៀនដែលយកមកលាក់ទុកនោះ ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ៣៥៤១ អ.យ.ឍ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២ ។

**-បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៩៥៩ "ខ" ង.ង ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២ ។

-ជនជាប់ចោទឈ្មោះ [redacted] ម៉េងគង់ ហៅ ម៉ាប់ បានឆ្លើយថា៖ ខ្លួនស្គាល់ឈ្មោះ [redacted] ឡេងប៊ុនរ៉ា ដែលកំពុងជាប់ឃុំក្នុងពន្ធនាគារព្រៃស តាមរយៈឈ្មោះ ឃួន បានណែនាំឱ្យខ្លួនទំនាក់ទំនងទៅឈ្មោះ [redacted] ឡេងប៊ុនរ៉ា តាមរយៈគណនីហ្វេសប៊ុកឈ្មោះ ស្រលាញ់ស្មោះ ។ ក្រោយពីខ្លួនបានទំនាក់ទំនងជាមួយឈ្មោះ [redacted] ឡេងប៊ុនរ៉ា តាមរយៈតាពបក នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២ ឈ្មោះ [redacted] ឡេងប៊ុនរ៉ា បានប្រើឱ្យខ្លួនឡើងទៅខេត្តកំពង់ឆ្នាំង ដើម្បីយកគ្រឿងញៀនពីមនុស្សម្នាក់មិនស្គាល់ឈ្មោះ ដោយប្រើលេខទូរស័ព្ទ ០៩៧ ៩៧៦ ៧២៤៥ ។ ខ្លួនក៏បានជួលរថយន្តម៉ាកហាយឡែនឌឺ ជិះទៅតែម្នាក់ឯង ពេលទៅដល់ខេត្តកំពង់ឆ្នាំង ម្ចាស់លេខទូរស័ព្ទ ០៩៧ ៩៧៦ ៧២៤៥ ជាមនុស្សប្រុសបានប្រាប់មកខ្លួនវិញថាមិនមានថ្នាំញៀនទេ ឱ្យខ្លួនត្រលប់មកវិញសិនទៅ ខ្លួនពុំបានដឹងថាខ្លួនទៅទទួលថ្នាំញៀនចំនួនប៉ុន្មាននោះទេ ។ ក្រោយមកនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ១១ និង ០០ នាទី ឈ្មោះ [redacted] ឡេងប៊ុនរ៉ា បានណាត់មកខ្លួនឱ្យទៅម្តុំតំបន់សេដ្ឋកិច្ចពិសេសនៅកំបូលដើម្បីយកឡាន និងកាំភ្លើងពីឈ្មោះ ម៉ៅ ភេទប្រុស អាយុប្រហែល ៣២ឆ្នាំ ប្រើប្រាស់លេខទូរស័ព្ទ ០១០ ៧០៥ ៧៥៩ ។ ពេលទៅដល់ខ្លួនក៏ទទួលរថយន្តប៉ាកព្រូស ពណ៌មាស ពាក់ស្លាកលេខ ភ្នំពេញ ២AX-០៣៣១ និងកាំភ្លើងម៉ាក GLOCK 19 ចំនួន ០១ ដើម ពីឈ្មោះ ម៉ៅ ប៉ុន្តែខ្លួនពុំបានសួរថាជាកាំភ្លើងរបស់អ្នកណានោះទេ ទាំងឈ្មោះ [redacted] ឡេងប៊ុនរ៉ា និងឈ្មោះ ម៉ៅ រួចខ្លួនក៏បានត្រលប់ទៅផ្ទះជួលរបស់ខ្លួននៅបុរីចំការដូង វិញ ។ នៅវេលាម៉ោងប្រហែល ០៥ ល្ងាច ខ្លួនក៏បានជិះម៉ូតូកង់បីទៅទទួលសង្សារឈ្មោះ [redacted] សេងហួរសុម៉ារី នៅភ្នំតាម៉ៅ ផ្ទះរបស់ឈ្មោះ [redacted] សុគន្ធារី ដែលត្រូវជាប្រពន្ធរបស់ឈ្មោះ [redacted] ឡេងប៊ុនរ៉ា ។ នៅវេលាម៉ោងប្រហែល ១២ យប់ ចូលថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ ខ្លួន និងឈ្មោះ សេវីត ភេទប្រុស អាយុប្រហែល ២៣ ឆ្នាំ ជនជាតិខ្មែរ កាន់ទូរស័ព្ទលេខ ០៨៧ ៩២៤ ៩៤១ ជាប្អូនៗដែលខ្លួនរាប់អានបានធ្វើដំណើរទៅខេត្តពោធិ៍សាត់ដោយជិះរថយន្តប៉ាកព្រូស និងយកកាំភ្លើងខាងលើទៅតាមខ្លួនដើម្បីទៅយកថ្នាំញៀនតាមការណែនាំរបស់ឈ្មោះ [redacted] ឡេងប៊ុនរ៉ា ដោយឱ្យទំនាក់ទំនងទៅបុរសម្នាក់មិនស្គាល់ឈ្មោះ ប្រើទូរស័ព្ទលេខ ០៩៧ ៩៧៦ ៧២៤៥ ពេលខ្លួនទំនាក់ទំនងទៅក៏បានយកថ្នាំញៀនមួយចំនួនដាក់ក្នុងបាវ រួចក៏ត្រលប់មកភ្នំពេញវិញជាមួយឈ្មោះ សេវីត ហើយខ្លួនក៏យកថ្នាំញៀននេះទៅទុកនៅផ្ទះជួលរបស់ខ្លួនខាងលើនៅចំការដូង ។ ក្រោយមកនៅវេលាម៉ោងប្រហែល ១៣ ថ្ងៃខែឆ្នាំដដែល ឈ្មោះ [redacted] ឡេងប៊ុនរ៉ា បានណាត់មកខ្លួនឱ្យយកកាំភ្លើងខាងលើនេះទៅប្រគល់ឱ្យប្រពន្ធឈ្មោះ [redacted] សុគន្ធារី នៅតាម៉ៅ ក្រោយពេលប្រគល់កាំភ្លើងឱ្យទៅឈ្មោះ [redacted] សុគន្ធារី រួច ខ្លួន និងសង្សារឈ្មោះ [redacted] សេងហួរសុម៉ារី ក៏បានត្រលប់មកផ្ទះជួលរបស់ខ្លួនវិញ ហើយខ្លួនក៏បានយករថយន្តបកលាង ។ លុះវេលាម៉ោងប្រហែល ១៧ ថ្ងៃខែឆ្នាំដដែល ពេលខ្លួនត្រលប់មកដល់ផ្ទះជួល ក្រោយពេលលាងរថយន្តរួចមិនទាន់បានចូលក្នុងផ្ទះផង ក៏ត្រូវបានសមត្ថកិច្ចមួយក្រុមឃាត់ខ្លួន ដោយប្រាប់ថាពាក់ព័ន្ធនឹងគ្រឿងញៀន ។ ខ្លួនឆ្លើយថាគ្រឿងញៀនអត់គេ ខាងសមត្ថកិច្ចក៏បានសុំចូលឆែកឆេរក្នុងផ្ទះរបស់ខ្លួនរកឃើញថ្នាំញៀននៅក្នុងបន្ទប់ផ្ទះជួលរបស់ខ្លួន ដែលថ្នាំញៀននោះខ្លួនយកពីខេត្តពោធិ៍សាត់ ។ បន្ទាប់មកខ្លួនក៏នាំសមត្ថកិច្ចទៅឆែកឆេរនៅផ្ទះរបស់ឈ្មោះ [redacted] សុគន្ធារី រកឃើញ កាំភ្លើងម៉ាក GLOCK 19 ចំនួន ០១ ដើម និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ [redacted] ឡេងប៊ុនរ៉ា ។ ខ្លួនចេះរកស៊ីជួញដូរ និងប្រើប្រាស់គ្រឿងញៀន នេះចាប់តាំងពីអំឡុងខែមិនា ឆ្នាំ២០២០ មកម្លេះ ប៉ុន្តែពុំមានសល់ទ្រព្យសម្បត្តិ ឬ អចលនវត្ថុអ្វីនោះទេ ដោយខ្លួនទើបតែមករស់នៅរាជធានីភ្នំពេញ ០៤ ទៅ ០៥ ខែ នេះប៉ុណ្ណោះ ។ ចំពោះសកម្មភាពរបស់ឈ្មោះ [redacted] ឡេងប៊ុនរ៉ា ដែលប្រើខ្លួននោះគេបានសន្យាថា នឹងឱ្យរថយន្តព្រូស ០១ គ្រឿងមកខ្លួន ។ ខ្លួនសុំបញ្ជាក់ថាការងារនោះដឹងតែខ្លួន និងឈ្មោះ [redacted] ឡេងប៊ុនរ៉ា ព្រមទាំងឈ្មោះ សេវីត តែប៉ុណ្ណោះ ចំណែកឈ្មោះ [redacted] សុគន្ធារី និងឈ្មោះ [redacted] សេងហួរសុម៉ារី ពុំដឹងរឿងអ្វីនោះទេ នៅពេលខ្លួន

ប្រគល់កាំភ្លើងទៅឱ្យឈ្មោះ [redacted] **សុគន្ធារី** គេពុំដឹងថាជាកាំភ្លើងនោះដែរ ព្រោះខ្លួនបានវេចខ្ចប់ក្នុងកញ្ចប់ខ្មៅយ៉ាងជិត ។ ខ្លួនធ្លាប់បានទំនាក់ទំនងយកគ្រឿងញៀន តាមរយៈ MESSENGER ជាមួយនឹងឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** ដែលមានអាខោនហ្វេសប៊ុកឈ្មោះ ស្រលាញ់ស្មោះ អស់រយៈពេលប្រហែល ២ ខែ មកហើយ តាមរយៈមិត្តភក្តិខ្លួនឈ្មោះ **យួន** ដែលទើបនឹងចេញពីពន្ធនាគារ ដោយគេប្រាប់ថាបើឯងចង់រកស៊ីគ្រឿងញៀន ឱ្យទាក់ទងតាមហ្វេសប៊ុកនឹងទៅ ។

-ជនជាប់ចោទឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** ហៅ **ផាន់ណា** បានឆ្លើយថា៖ ខ្លួនព្រមទទួលស្គាល់បទល្មើស **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ដែលតំណាងអយ្យការចោទ ចុះថ្ងៃទី២២ ខែមិនា ឆ្នាំ២០២២ ។ សព្វថ្ងៃខ្លួនកំពុងជាប់ឃុំនៅមណ្ឌលអប់រំកែប្រែទី១ ហើយប្រពន្ធខ្លួនឈ្មោះ [redacted] **សុគន្ធារី** មានកូនចំនួន០១នាក់ ។ ពេលកំពុងជាប់ឃុំខ្លួនបានលួចប្រើទូរស័ព្ទ ដោយលួចយកទូរស័ព្ទចូលតាមរយៈការផ្ញើអីវ៉ាន់ ។ ក្នុងបន្ទប់ឃុំឃាំង មានកន្លែងខ្លះមានប្រព័ន្ធសេវាអាចប្រើអ៊ិនធឺណែតបាន ហើយកន្លងមកខ្លួនតែងតែលួចតេមកប្រពន្ធតាមរយៈវីឌីអូខល និងតេមកមិត្តភក្តិដែលធ្លាប់ស្គាល់នៅខាងក្រៅ ដើម្បីទំនាក់ទំនងនិយាយការងារ និងសួរសុខទុក្ខគ្នា ។ ពេលនិយាយជាមួយគ្នាមិត្តភក្តិខ្លួនក៏បានណែនាំឱ្យខ្លួនស្គាល់ឈ្មោះ [redacted] **ម៉េងគង់** ដើម្បីទំនាក់ទំនងឱ្យឈ្មោះ [redacted] **ម៉េងគង់** ជួយទំនាក់ទំនងរកស៊ីគ្រឿងញៀន ។ លុះដល់ថ្ងៃកើតហេតុកាលពីអំឡុង ថ្ងៃទី១៣ ខែមិនា ឆ្នាំ២០២២ ខ្លួនក៏បានទាក់ទងតាមរយៈទូរស័ព្ទទៅឈ្មោះ [redacted] **ម៉េងគង់** ឱ្យទៅយករថយន្តម៉ាកព្រុស និងកាំភ្លើងខ្លី ០១ ដើម ពីឈ្មោះ **ម៉ៅ** នៅម្តុំតំបន់សេដ្ឋកិច្ចពិសេស ដោយរថយន្តនោះជារបស់ឈ្មោះ **ម៉ៅ** ហើយកាំភ្លើងខ្លីនោះជារបស់ខ្លួន ដែលបានទិញពីគេជាយូរមកហើយនៅប៉ោយប៉ែត ហើយបានផ្ញើទុកនៅឈ្មោះ **ម៉ៅ** មុនពេលខ្លួនជាប់ពន្ធនាគារទៅទៀត ។ នៅពេលដែលបានយករថយន្ត និងកាំភ្លើង បានហើយ ខ្លួនឱ្យឈ្មោះ [redacted] **ម៉េងគង់** ទៅយកថ្នាំញៀននៅខេត្តពោធិ៍សាត់ជិតរង្វង់មូលភ្លើល ពីឈ្មោះ **ភី** ភេទប្រុស ដែលគេយកមកប្តូរនៅការ៉ាសសាំងតេឡាជិតរង្វង់មូលភ្លើល ។ កន្លងមកខ្លួនស្គាល់ឈ្មោះ **ភី** អស់រយៈពេល ០២ ឆ្នាំ មកហើយ និងធ្លាប់ឱ្យគេទទួលថ្នាំញៀនពីឈ្មោះ **ភី** ចំនួន ០២ លើក តែមិនដឹងតម្លៃ និងចំនួនគីឡូប៉ុន្មានទេ គ្រាន់តែទៅទទួលពីខេត្តពោធិ៍សាត់ ទៅម្តុំកាស៊ីណូជ្រៃធំ ។ កន្លងមកមុនខ្លួនជាប់ឃុំ ប្រពន្ធខ្លួនឈ្មោះ [redacted] **សុគន្ធារី** មិនដែលដឹងថាខ្លួនមានកាំភ្លើងខ្លីសម្រាប់ប្រើប្រាស់ទេ ពីព្រោះខ្លួនមិនដែលយកមកទុកនៅផ្ទះឱ្យគេឃើញឡើយ ទើបតែនៅពេលដែលឈ្មោះ [redacted] **ម៉េងគង់** មកពីយកគ្រឿងញៀននៅខេត្តពោធិ៍សាត់វិញ ខ្លួនក៏បានប្រាប់ឈ្មោះ [redacted] **ម៉េងគង់** ឱ្យរុំកាំភ្លើងនោះឱ្យជិត ហើយយកទៅឱ្យប្រពន្ធខ្លួន ដោយប្រាប់ថាឱ្យទុកឱ្យបង ហើយកុំបើកមើលឱ្យទុកនៅទូរដែក ទៅស្អែកមានគេមកយកហើយ ទើបប្រពន្ធខ្លួនមិនហ៊ានបើកមើលក្នុងកញ្ចប់ខ្មៅនោះ ។

-ជនជាប់ចោទឈ្មោះ [redacted] **សេងហួរសុផារី** បានឆ្លើយថា៖ ខ្លួន និងឈ្មោះ [redacted] **ម៉េងគង់** ត្រូវជាសង្សារនឹងគ្នាអស់រយៈពេល ០៤ ខែមកហើយ ដោយខ្លួនចេញចូលផ្ទះរបស់ឈ្មោះ [redacted] **ម៉េងគង់** នៅថ្ងៃឈប់រៀន ហើយជួនកាលខ្លួនឧស្សាហ៍ឡើងចុះពីស្រុកកំណើតខេត្តកំពង់ចាម ។ នៅថ្ងៃទី១២ ខែមិនា ឆ្នាំ២០២២ ពេលដែលខ្លួនត្រលប់មកផ្ទះឈ្មោះ [redacted] **ម៉េងគង់** ក៏បានឃើញឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួននៅក្នុងកន្ត្រកដួល ពេលនោះខ្លួនសង្ស័យថាឈ្មោះ [redacted] **ម៉េងគង់** លេងប្រើប្រាស់ថ្នាំញៀន ។ នៅថ្ងៃទី១៥ ខែមិនា ឆ្នាំ២០២២ ពេលដែលខ្លួននៅជាមួយឈ្មោះ [redacted] **ម៉េងគង់** ស្រាប់តែមានសំឡេងទូរស័ព្ទខលចូលតាមគណនីហ្វេសប៊ុករបស់ឈ្មោះ [redacted] **ម៉េងគង់** ហើយពេលនោះឈ្មោះ [redacted] **ម៉េងគង់** បានកាន់ទូរស័ព្ទដើរចេញពីខ្លួនទៅនិយាយខាងក្រៅបាត់ ខ្លួនមិនដឹងថា និយាយជាមួយនរណា និងនិយាយពីអ្វីនោះទេ ។ នៅវេលាម៉ោងប្រហែល ១៧ ថ្ងៃខែឆ្នាំដដែល ឈ្មោះ [redacted] **ម៉េងគង់** បានជូនខ្លួនឱ្យទៅគេងនៅផ្ទះរបស់ឈ្មោះ [redacted] **សុគន្ធារី** ដោយនិយាយថាជាបងស្រីរាប់អានគ្នា ។ ពេលទៅដល់ស្រាប់តែឈ្មោះ [redacted] **ម៉េងគង់** បាត់ត្រលប់មកវិញ ហើយប្រាប់ថាទៅធ្វើការងារ ។ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ១៤ ឈ្មោះ

[redacted] **ម៉េងគង់** បានត្រលប់មកយកខ្លួនវិញ មុនពេលមកផ្ទះឈ្មោះ [redacted] **ម៉េងគង់** បានហុចថង់មកឱ្យខ្លួន រួចក៏បន្តទៅឱ្យឈ្មោះ [redacted] **សុគន្ធារី** ជាអ្នកទុក ។ នៅវេលាម៉ោង ១៧ ថ្ងៃខែឆ្នាំដដែល ពេលឈ្មោះ [redacted] **ម៉េងគង់** ត្រឡប់មកពីលាងរថយន្តវិញបើកទ្វារបម្រុងចូលផ្ទះក៏ត្រូវបានសមត្ថកិច្ចចូលមកឃាត់ខ្លួន និងបានឆែកឆេររកឃើញថ្នាំញៀនចំនួន ៦០ ដុំ ទើបខ្លួនដឹងថាឈ្មោះ [redacted] **ម៉េងគង់** បានធ្វើសកម្មភាពដឹកជញ្ជូនរក្សាទុកគ្រឿងញៀនខុសច្បាប់ ។ ខ្លួនពុំដែលស្គាល់ឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** នោះទេ ចំណែកឯបងស្រីឈ្មោះ [redacted] **សុគន្ធារី** ខ្លួនស្គាល់តាមរយៈសង្សារឈ្មោះ [redacted] **ម៉េងគង់** ក្រៅពីនោះខ្លួនពុំបានដឹងអីទេ ។ ចំពោះថ្នាំញៀនដែលសមត្ថកិច្ចរកឃើញនៅក្នុងផ្ទះរបស់ខ្លួននោះ ខ្លួនពុំដឹងថាឈ្មោះ [redacted] **ម៉េងគង់** យកបកលាក់ទុកពីពេលណានោះទេ ។

-ជនជាប់ចោទឈ្មោះ [redacted] **សុគន្ធារី** បានឆ្លើយថា៖ ខ្លួន និងឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** ត្រូវជាប្តីប្រពន្ធនឹងគ្នា និងបានរួមរស់ជាមួយគ្នាចាប់តាំងពីឆ្នាំ២០១៨ មកម្លេះ មានកូនស្រីចំនួន ០២ នាក់ ដោយពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ ។ ក្រោយមកនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ប្តីខ្លួនត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួនបញ្ជូនទៅពន្ធនាគារព្រៃស ក្នុងករណី លួច ។ ចាប់តាំងពីប្តីខ្លួនជាប់ពន្ធនាគារមកគាត់តែងតែទំនាក់ទំនងមកខ្លួនតាមរយៈហ្វេសប៊ុករបស់គេឈ្មោះ "ស្រលាញ់ស្នេហ៍" ពីមុន ឈ្មោះ "ប្តីល្អ" ។ ពេលគាត់ទំនាក់ទំនងមកម្តងៗ គ្មានអ្វីក្រៅពីសុំមើលមុខកូនតែប៉ុណ្ណោះ មិនដែលនិយាយអ្វីផ្សេងទេ ។ លុះដល់ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២ ប្តីខ្លួនបានណែនាំឱ្យស្គាល់ឈ្មោះ [redacted] **ម៉េងគង់** តាមរយៈ MESSENGER ។ ក្រោយមកឈ្មោះ [redacted] **ម៉េងគង់** បាននាំសង្សារឈ្មោះ [redacted] **ផេងហួរសុផារី** មកលេងផ្ទះខ្លួន ដោយបានទិញសៀវវ៉ៃ និងផាខ្វៃមកឱ្យខ្លួន ។ លុះស្អែកឡើងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ វេលាប្រហែល ៦ ល្ងាច ឈ្មោះ [redacted] **ម៉េងគង់** បាននាំសង្សារគេឱ្យគេងផ្ទះខ្លួន ហើយគាត់ត្រឡប់ទៅវិញ ដោយទុកសង្សារគេឱ្យសម្រាកនៅផ្ទះខ្លួនមួយយប់ ។ លុះដល់ថ្ងៃទី១៦ ខែឆ្នាំដដែល ម៉ោងប្រហែល ២ រសៀល ឈ្មោះ [redacted] **ម៉េងគង់** បានមកយកសង្សារគេវិញ និងបានហុចកញ្ចប់ខ្មៅមួយរុំបិទជិតឱ្យទៅសង្សារគេឈ្មោះ [redacted] **ផេងហួរសុផារី** រួចសង្សារគេក៏ហុចឱ្យខ្លួនបន្ត ដោយប្រាប់ថាយកទុកផង ហើយខ្លួនក៏មិនបានបើកមើល មិនសួរនាំអ្វីទេ ក៏បានយកកញ្ចប់ខ្មៅនោះទៅដាក់ក្នុងទូរដែក ពីព្រោះរវល់មើលកូនតូចកំពុងយំ ។ នៅថ្ងៃខែឆ្នាំដដែល វេលាម៉ោងប្រហែល ៧ និង ៣០ នាទី ល្ងាច ឈ្មោះ [redacted] **ម៉េងគង់** បាននាំសមត្ថកិច្ចឆែកឆេរផ្ទះខ្លួន រួចក៏បើកទូរដែកយកកញ្ចប់ខ្មៅនោះមកបើលក៏ឃើញកាំភ្លើងខ្លី ពេលនោះទើបខ្លួនដឹងថានៅក្នុងកញ្ចប់ខ្មៅនោះជាកាំភ្លើងខ្លី ហើយសមត្ថកិច្ចក៏បានឃាត់ខ្លួនតែម្តង ។ ចំពោះករណីគ្រឿងញៀនខ្លួនមិនបានដឹងទេ ពីព្រោះខ្លួនជាប់រវល់មើលកូនតូច ក្មួយ ២ នាក់ និង ម្តាយក្មេកដែលចាស់ជរា ។

-លោក វរសេនីយ៍ទោ [redacted] **ភាព** តំណាងមន្ទីរប្រឆាំងគ្រឿងញៀន បានឆ្លើយថា ៖ កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ មានពិរុទ្ធជនដែលកំពុងជាប់ពន្ធនាគារ "ម២" បានរាយការណ៍បកបន្ត្រីការិយាល័យផ្សព្វផ្សាយ អប់រំ (ក៤) មន្ទីរប្រឆាំងគ្រឿងញៀនថា មានមុខសញ្ញាសង្ស័យជាទណ្ឌិតឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** ហៅ **ផាត់ណា** បានធ្វើសកម្មភាពបញ្ជាចាត់ចែងឱ្យបក្ខពួក ដឹកជញ្ជូន ដោយខុសច្បាប់នូវសារធាតុញៀន ។ លុះដល់ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ១៧ និង ២០ នាទី មន្ទីរប្រឆាំងគ្រឿងញៀន បានបង្ក្រាបនៅចំណតបុរីចំការដូង ផ្ទះលេខF ៣០ ផ្លូវបេតុង សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ និងឃាត់ខ្លួនឈ្មោះ វ៉ា ម៉េងគង់ ដែលទើបបើកឡានមកដល់ ហើយឆែកឆេរក្នុងផ្ទះឃើញមានវត្ថុតាងក្រោមពណ៌សថ្លា ប្រភេទហេរ៉ូអ៊ីន និងមេតំហ្វេតាមីន ទម្ងន់ ០១.២៣៥,០៤ ក្រាម ហើយសមត្ថកិច្ចក៏បានឃាត់ខ្លួនឈ្មោះ [redacted] ម៉េងគង់ ។ នៅពេលសមត្ថកិច្ចកំពុងបង្ក្រាបនៅទីតាំងខាងលើ ឈ្មោះ [redacted] ផេងហួរសុផារី កំពុងនៅផ្ទះខាងលើនេះដែរ ហេតុនេះ សមត្ថកិច្ចក៏បានឃាត់ខ្លួនឈ្មោះ ហ៊ីម សេងហួរ សុផារីមកជាមួយផងដែរ ។ សមត្ថកិច្ចក៏បានបន្តទៅឆែកឆេរផ្ទះរបស់ឈ្មោះ [redacted] សុគន្ធារី ស្ថិតនៅផ្ទះលេខ៥៦៤

ក្រុមទី១៧ ភូមិព្រែកភាំង១ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល រកឃើញវត្ថុតាងកាំភ្លើងខ្លីមួយដើមម៉ាក G LOCK 19 នៅក្នុងកញ្ចប់ខ្មៅបិទជិត ដាក់នៅក្នុងទូរដែក ទើបសមត្ថកិច្ចឃាត់ខ្លួនឈ្មោះ គង់ សុគន្ធារី ដើម្បីសាកសួរ និងបញ្ជូនមកតុលាការ ។

-តតិយជនឈ្មោះ [redacted] ហួរ បានឆ្លើយថា ៖ ខ្លួនជាម្ចាស់ផ្ទះលេខF៣០ ផ្លូវបេតុង ភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌ ដង្កោ រាជធានីភ្នំពេញ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៥០១០៣-០៩២៧ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ។ កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ ខ្លួនបានជួលផ្ទះនេះឱ្យទៅឈ្មោះ [redacted] ធារី ភេទស្រី អាយុ ៥០ឆ្នាំ ដែលត្រូវជាម្តាយរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉េងគង់ ក្នុងមួយខែ ២៥០ (ពីររយហាសិប) ដុល្លារអាមេរិក ។ ការជួលផ្ទះនេះ ខ្លួនបានធ្វើឯកសារចុះសន្យាជួលផ្ទះចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ និងបានចុះហត្ថលេខា និងឮពីអាជ្ញាធរត្រឹមត្រូវតាមច្បាប់ ។ ខ្លួនបានប្រគល់សោរផ្ទះឱ្យទៅអ្នកជួលនៅថ្ងៃទី១៥ ពេលល្ងាច លុះព្រឹកឡើងថ្ងៃទី១៦ ឈ្មោះ [redacted] ធារី ក៏បានមករៀបចំសម្អាតផ្ទះដើម្បីស្នាក់នៅ តែមិនទាន់បានស្នាក់នៅផងនៅពេលរសៀល ម៉ោង ប្រហែល២ ក៏មានសមត្ថកិច្ចមកចាប់ខ្លួនឈ្មោះ [redacted] ម៉េងគង់ នៅមុខផ្ទះដែលខ្លួនបានជួលពាក់ព័ន្ធនឹងករណីគ្រឿងញៀន បន្ទាប់មកសមត្ថកិច្ចបានបិទផ្ទះរបស់ខ្លួននៅពេលនោះតែម្តង ។ ខ្លួនសូមសំណូមពរឱ្យតុលាការជួយបើកផ្ទះដើម្បីឱ្យខ្លួនយកទៅប្រើប្រាស់ និងអាស្រ័យផលបន្តទៀត ។

-តតិយជនឈ្មោះ [redacted] សេង បានឆ្លើយថា ៖ ខ្លួនជាម្ចាស់ផ្ទះល្វែង B៣ (៥៩៤) ផ្លូវលំ ភូមិព្រែកភាំង១ សង្កាត់កំពង់ សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល ។ កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៨ ខ្លួនបានជួលផ្ទះនេះឱ្យទៅឈ្មោះ [redacted] ភឿន ដើម្បីស្នាក់នៅជាបណ្តោះអាសន្ន ។ ក្រោយមក ខ្លួនបានទទួលដំណឹងថា ផ្ទះនេះត្រូវបានតុលាការសម្រេចបិទទ្វារជាបណ្តោះអាសន្ន ។ ខ្លួនស្នើសុំបើកផ្ទះល្វែង B3៣ (៥៩៤) ផ្លូវលំ ភូមិព្រែកភាំង១ សង្កាត់កំពង់ សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល ដើម្បីគ្រប់គ្រង ប្រើប្រាស់ អាស្រ័យផល និងចាត់ចែង ជាកម្មសិទ្ធិឡើងវិញ ។

**សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ**

ក្រោយពីបានសួរដេញដោល និងពិនិត្យឯកសារក្នុងសំណុំរឿងឃើញថា ផ្អែកតាមការដេញដោលនាពេលសវនាការឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ ពិតប្រាកដមែន ។ ហេតុដូច្នេះ តំណាងអយ្យការសុំតម្កល់សេចក្តីចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរទុកជាបានការទាំងស្រុង និងស្នើសុំតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

**សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ**

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុគន្ធារី និងឈ្មោះ [redacted] ឡេង ប៊ុនរ៉ា បានធ្វើសេចក្តីសន្និដ្ឋានថា៖ ជាដំបូងខ្លួនសូមធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងឈ្មោះ [redacted] ឡេងប៊ុនរ៉ា ចំពោះកូនក្តីខ្លួនឈ្មោះ [redacted] ឡេងប៊ុនរ៉ា ចាប់តាំងពីតំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ រហូតដល់តំណាក់កាលជំនុំជម្រះឃើញថា កូនក្តីខ្លួនបានសារភាពនូវទង្វើដែលបានធ្វើ គឺកូនក្តីខ្លួនបានឱ្យឈ្មោះ [redacted] ម៉េងគង់ យកឡានទៅដឹកជញ្ជូនគ្រឿងញៀនឱ្យគេ ដែលបញ្ជាក់ថា កូនក្តីខ្លួនគ្រាន់តែស៊ីឈ្នួលដឹកឱ្យគេប៉ុណ្ណោះ គ្រឿងញៀនទាំងនោះមិនមែនជារបស់កូនក្តីខ្លួននោះទេ ។ សូមតុលាការពិចារណាផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួនផង ។

ចំពោះកូនក្តីខ្លួនឈ្មោះ [redacted] សុគន្ធារី ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការឃើញថា កូនក្តីខ្លួនបានទទួលយកកញ្ចប់ខ្មៅទៅទុកពិតមែន ប៉ុន្តែមិនបានដឹងថាក្នុងកញ្ចប់ខ្មៅនោះមានកាំភ្លើងនោះទេ ។ កូនក្តីខ្លួនយកកញ្ចប់ខ្មៅទៅរក្សាទុកដោយសារជនជាប់ចោទឈ្មោះ [redacted] ឡេងប៊ុនរ៉ា ដែលត្រូវជាប្តីរបស់កូនក្តីខ្លួនប្រាប់ឱ្យយកទុក ហេតុនេះ កូនក្តីខ្លួនក៏ធ្វើតាមប្តីប្រាប់ដោយមិនបានសួរនាំបញ្ជាក់ថាជាអ្វីនោះទេ ហើយនៅពេលឈ្មោះ [redacted]



Scanned with CamScanner

**ម៉េងគង់** យកកញ្ចប់ខ្មៅមកឱ្យ កូនក្តីខ្លួនមិនបានស្រាយមើលទេ គឺយកទៅទុកទាំងសភាពដើមទាំងអស់ ។ ស្រប ជាមួយគ្នានេះដែរ មន្ត្រីនគរបាលយុត្តិធម៌ក៏បានបញ្ជាក់ដែរថា បានរកឃើញកញ្ចប់ខ្មៅនៅក្នុងទូរដែក ហើយនៅពេលស្រាយមើលទើបឃើញកាំភ្លើងនៅក្នុងនោះ បើមើលពីខាងក្រៅមិនអាចដឹងថាក្នុងកញ្ចប់ខ្មៅនោះមានអ្វីនោះទេ ។ ខ្លួនសូមសំណូមពរតុលាការមេត្តាពិនិត្យ និងសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សុគន្ធារី** បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនមិនមានចេតនាប្រព្រឹត្តបទល្មើសនោះទេ កូនក្តីខ្លួនមិនដឹងថា នៅក្នុងថង់ខ្មៅមានកាំភ្លើងនោះឡើយ ហើយជនជាប់ចោទឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** និងឈ្មោះ [redacted] **ម៉េងគង់** ក៏បានបញ្ជាក់ដែរថា ឈ្មោះ [redacted] សុគន្ធារី មិនដឹងនោះទេថាមានកាំភ្លើងនៅក្នុងកញ្ចប់ខ្មៅព្រោះពួកគេគ្រាន់តែយកកញ្ចប់ខ្មៅឱ្យឈ្មោះ [redacted] **សុគន្ធារី** ទុកប៉ុណ្ណោះ និងមិនបានប្រាប់ថាជាអ្វីនោះទេ ។ តាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ បានចែងថា ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ។ ជាក់ស្តែងសមត្ថកិច្ចក៏បានបញ្ជាក់ដែរថា នៅពេលសមត្ថកិច្ចឆែកឆេរ ឃើញមានកញ្ចប់ខ្មៅបិទជិតដែលមិនអាចមើលដឹងថា មានអ្វីនៅក្នុងកញ្ចប់ខ្មៅនោះទេ ទាល់តែបើកចេញទើបឃើញមានកាំភ្លើងនៅក្នុងថង់ខ្មៅនោះ ។ ចំណុចទាំងអស់នេះជាវិមតិសង្ស័យ ហេតុនេះ សូមតុលាការមេត្តាលើកលែងចោទប្រកាន់ដល់កូនក្តីខ្លួន ដោយពិចារណាលើវិមតិសង្ស័យត្រូវតែបានជាអត្ថប្រយោជន៍ដល់ជនជាប់ចោទជានិច្ច តាមមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ម៉េងគង់** និងឈ្មោះ [redacted] **ផេងហួរសុដាវី** បានធ្វើសេចក្តីសន្និដ្ឋានថា៖ ជាដំបូងខ្លួនសូមធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងឈ្មោះ [redacted] **ម៉េងគង់** ក្រោយពីបានស្តាប់ការឆ្លើយដោយផ្ទាល់នាពេលសវនាការ ឃើញថា កូនក្តីខ្លួនបានសារភាពកំហុសទាំងពីចំណាក់ការមន្ត្រីនគរបាលយុត្តិធម៌ រហូតមកដល់ចំណាក់ការចៅក្រមស៊ើបសួរ និងបានសហការផ្តល់ព័ត៌មានពាក់ព័ន្ធទៅនឹងអង្គហេតុនេះផងដែរ ។ ក្រោយពេលបានជាប់ពន្ធនាគារកូនក្តីខ្លួនបានភ្ញាក់រលឹក និងមានការសោកស្តាយចំពោះទង្វើរបស់ខ្លួន ហើយមានចេតនាកែប្រែកំហុស ដើម្បីវិលទៅរស់នៅសង្គមវិញ ។ ទង្វើរបស់កូនក្តីខ្លួនកើតឡើងដោយសារមិនបានគិតឱ្យបានវែងឆ្ងាយ និងគិតខុសមួយពេល ដោយផ្តោតតែទៅលើការរកប្រាក់ដើម្បីផ្គត់ផ្គង់ជីវភាព ។ ហេតុដូចនេះ ខ្លួនស្នើសុំតុលាការមេត្តាផ្តល់ស្ពានសម្រាលទោសផ្តល់នូវកំរិតទោសអប្បបរមាដល់កូនក្តីខ្លួនផង ។

ចំពោះកូនក្តីខ្លួនឈ្មោះ [redacted] ផេងហួរសុដាវី ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការឃើញថា កូនក្តីខ្លួនមិនបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់នោះទេ ដោយហេតុថា កូនក្តីខ្លួនទើបមកកន្លែងកើតហេតុបានចំនួនពីរថ្ងៃ គឺមកជួបជនជាប់ចោទឈ្មោះ [redacted] **ម៉េងគង់** ដែលត្រូវជាសង្សារ ។ មួយវិញទៀត តាមការបញ្ជាក់របស់មន្ត្រីនគរបាលយុត្តិធម៌ក៏បានបញ្ជាក់នាពេលសវនាការនេះដែរថា កូនក្តីខ្លួនមិនបានប្រព្រឹត្តបទល្មើសជាក់ស្តែង នោះទេ គ្រាន់តែកូនក្តីខ្លួនមានវត្តមាននៅផ្ទះ ដែលសមត្ថកិច្ចចុះបង្ក្រាបតែប៉ុណ្ណោះ ។ ហេតុដូចនេះ សូមតុលាការមេត្តាលើកលែងទោសដល់កូនក្តីខ្លួន ។

**សម្តីចុងក្រោយរបស់ជនជាប់ចោទ**

-ជនជាប់ចោទឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** ស្នើសុំតុលាការជួយបន្ធូរបន្ថយទោស ខ្លួនដឹងកំហុសហើយ ។

-ជនជាប់ចោទឈ្មោះ [redacted] **ម៉េងគង់** ស្នើសុំតុលាការជួយបន្ធូរបន្ថយទោស ។

-ជនជាប់ចោទឈ្មោះ [redacted] **ផេងហួរសុដាវី** ស្នើសុំតុលាការជួយរកយុត្តិធម៌ដល់ខ្លួនផង ។

-ជនជាប់ចោទឈ្មោះ [redacted] **សុគន្ធារី** ស្នើសុំតុលាការជួយរកយុត្តិធម៌ដល់ខ្លួនផង ។

ក្រោយពីបានសួរដេញដោលក្នុងអង្គសវនាការ



Scanned with CamScanner

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ និងមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាលើសំណុំរឿងត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

១-តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៩៤៩ "ខ" ង.ជ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២ ទៅក្រុមស៊ើបសួរ បានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** ភេទប្រុស អាយុ ៣៥ឆ្នាំ ឈ្មោះ [redacted] **ម៉េងគង់** ភេទប្រុស អាយុ ៣០ឆ្នាំ និងឈ្មោះ [redacted] **សេងហួរសុដារី** ភេទស្រី អាយុ ២០ឆ្នាំ ទៅជំនុំជម្រះពីបទ **ដឹកជញ្ជូន និង ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចបុរីចំការដូងផ្ទះលេខ F៣០ ផ្លូវបេតុង សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ និងខេត្តពោធិ៍សាត់ កាលពីអំឡុងខែមីនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២២ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ និងថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងឈ្មោះ [redacted] **សុគន្ធារី** ភេទស្រី អាយុ ៣៧ឆ្នាំ ទៅជំនុំជម្រះពីបទ **កាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** ប្រព្រឹត្តនៅចំណុចផ្ទះលេខ៥៩៤ ក្រុមទី១៧ ភូមិព្រែករាំង សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ ។

២-តាមកំណត់ហេតុធ្វើតេស្ត និងវេចខ្ចប់វត្ថុតាងលេខ ៤៧១ កណហ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ របស់មន្ត្រីបច្ចេកទេសនៃមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន បានបង្ហាញថា មន្ត្រីបច្ចេកទេសបានដំណើរការធ្វើតេស្តបឋមដោយការប្រើប្រាស់ឧបករណ៍ អ៉ិតតេស្ត ព្រមទាំងវេចខ្ចប់ និងថ្លឹងដោយប្រើប្រាស់ជញ្ជីងម៉ាក VIBRA ។ ជាលទ្ធផលឃើញថាសំណាកម្សៅប៉ិតពណ៌សសង្ស័យមានវត្ថុមានសារធាតុញៀនឈ្មោះ **ហេរ៉ូអ៊ីន** ចំនួន ៦០ ដុំ (១ ដុំទម្ងន់ ៣៥២,៨១ ក្រាម) មានទម្ងន់សរុប ២១.១៧៤.៦ (ម្ភៃមួយពាន់ មួយរយចិតសិបបួន ក្បៀសប្រាំមួយ) ក្រាម ចំណែកសំណាកគ្រាប់ពណ៌សផ្កាឈូកសង្ស័យមានវត្ថុមានសារធាតុញៀនឈ្មោះ **មេតំហ្វេតាមីន** មានទម្ងន់សរុប ០,៤៩ (សូន្យក្បៀសសែសិបប្រាំបួន) ក្រាម ។

៣-តាមកំណត់ហេតុស្តីពីការទទួលស្គាល់សម្ភារៈវត្ថុតាងលេខ ០២៦ កណហក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ របស់សមត្ថកិច្ចនគរបាលយុត្តិធម៌ នៃមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន ឃើញថា ឈ្មោះ [redacted] **ម៉េងគង់** បានទទួលស្គាល់ថា សំណាកចាប់យកនាពេលឃាត់ខ្លួនចំនួន ៦០ ដុំ សង្ស័យមានវត្ថុមានសារធាតុញៀន ពិតជាចាប់យកពីជនជាប់ចោទមែន ។

៤-តាមរបាយការណ៍លេខ ៣៦៣៥០/២២ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២ របស់មន្ទីរពិសោធន៍ ស្តីពីលទ្ធផលកោសល្យវិច័យលើសំណាកដែលចាប់យកនាពេលឃាត់ខ្លួនឈ្មោះ [redacted] **ម៉េងគង់** បានបង្ហាញថា៖

-**សំណាកទី១៖** ប្រភេទដុំម្សៅពណ៌ស មានវត្ថុមានសារធាតុញៀនឈ្មោះ **ហេរ៉ូអ៊ីន (Heroin)** ស្ថិតក្នុងតារាងទី១ នៃតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មានកម្រិតភាពសុទ្ធ **៨៣,២១%** នៃម៉ូលសរុប ។ ហេតុដូចនេះ ទម្ងន់សរុបនៃសារធាតុញៀន **ហេរ៉ូអ៊ីន** (Heroin) សរុបបានចំនួន **១៧.៦១៩,៣៨ ក្រាម (ដប់ប្រាំពីរពាន់ ប្រាំមួយរយដប់ប្រាំបួន ក្បៀសសាមសិបប្រាំបី)** ក្រាម (២១.១៧៤,៦ ក្រាម X ៨៣,២១/១០០) ។

**-សំណាកទី២៖** ប្រភេទក្រាបម្សៅពណ៌ស មានវត្ថុមានសារធាតុញៀនឈ្មោះ **មេតំហ្វេតាមីន** (ហៅក្រអាយ ឬម៉ាទឹកកក) ស្ថិតក្នុងតារាងទី២ នៃតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មានកម្រិតភាពសុទ្ធ **៧៩,៣២ %** នៃទម្ងន់សរុប ។ ហេតុដូចនេះ ទម្ងន់សរុបនៃសារធាតុញៀន **មេតំហ្វេតាមីន** សរុបមានចំនួន **០,៣៨ ក្រាម (សូន្យក្បៀសសាមសិបប្រាំបី) ក្រាម** (០,៤៩ ក្រាម X ៧៩,៣២/១០០) ។

៦-ជនជាប់ចោទឈ្មោះ [redacted] **ឡេងប៊ុនវ៉ា** និងឈ្មោះ [redacted] **ម៉េងគង់** បានទទួលស្គាល់ថា ពួកគេពិតជាបានធ្វើសកម្មភាពដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន មែន ។ ប៉ុន្តែជនជាប់ចោទបានបដិសេធថា ជនជាប់ចោទមិនបានធ្វើសកម្មភាពជួញដូរដោយខុសច្បាប់នូវសារធាតុញៀននោះទេ ។ ដោយឡែកជនជាប់ចោទឈ្មោះ [redacted] **ផេងហួរសុផារី** បានបដិសេធថា ខ្លួនមិនបានធ្វើសកម្មភាពដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន នោះទេ ។

៧-តាមរបាយការណ៍សមត្ថកិច្ច ចម្លើយសារភាពរបស់ជនជាប់ចោទ ក៏ដូចជាភស្តុតាងដែលមានក្នុងសំណុំរឿងមានភាពស៊ីសង្វាក់ដែលអាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] **ឡេងប៊ុនវ៉ា** និងឈ្មោះ [redacted] **ម៉េងគង់** ពិតជាមានការព្រមព្រៀងដោយផ្ទាល់ធ្វើសកម្មភាព **ដឹកជញ្ជូន និង ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ពិតប្រាកដមែន កាលពីកាលពីអំឡុងខែមីនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២២ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ និងថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ ប្រព្រឹត្តនៅចំណុចបុរីចិការម្លុងផ្ទះលេខF៣០ ផ្លូវបេតុង សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ និងខេត្តពោធិ៍សាត់ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ។

៨-ចម្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ [redacted] **ម៉េងគង់** និងឈ្មោះ [redacted] **ឡេងប៊ុនវ៉ា** ដែលថា ជនជាប់ចោទ មិនបានធ្វើសកម្មភាពជួញដូរដោយខុសច្បាប់នូវសារធាតុញៀន គ្រាន់តែជាការឆ្លើយដោះសារ និងមិនមានសំអាងបញ្ជាក់មកតុលាការនោះទេ ។ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ឡេងប៊ុនវ៉ា** នៅសមត្ថកិច្ចនគរបាលយុត្តិធម៌ឃើញថា ជនជាប់ចោទមិនមែនគ្រាន់តែជាអ្នករៀបចំនូវការដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀនប៉ុណ្ណោះ ទេ ។ ជនជាប់ចោទថែមទាំងជាអ្នករៀបចំទំនាក់ទំនងការទិញលក់ដោយខុសច្បាប់នូវសារធាតុញៀនថែមទៀតផង ។ នៅក្នុងខ្លឹមសារនៃចម្លើយរបស់ជនជាប់ចោទបានបង្ហាញឱ្យឃើញថា ឈ្មោះ **ហុង** ជាអ្នកទិញបញ្ជាទិញសារធាតុញៀន បានទំនាក់ទំនងមកជនជាប់ចោទ ហើយជនជាប់ចោទបានទំនាក់ទំនងទៅឈ្មោះ **ហ៊ា** ដើម្បីផ្សារភ្ជាប់ទំនាក់ទំនងនូវការលក់ទិញនេះទើបឈានដល់ការធ្វើសកម្មភាពដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន ។ តាមរយៈការធ្វើអន្តរការីក្នុងសកម្មភាពជួញដូរដោយខុសច្បាប់នូវសារធាតុញៀននេះបានបង្ហាញឱ្យឃើញថា ជនជាប់ចោទពិតជាបានចូលរួមក្នុងសកម្មភាពជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។ ដោយឡែកជនជាប់ចោទឈ្មោះ [redacted] **ម៉េងគង់** ជាបុគ្គលដែលជួយជនជាប់ចោទឈ្មោះ [redacted] **ឡេងប៊ុនវ៉ា** ក្នុងកិច្ចការដឹកជញ្ជូនសារធាតុញៀនពីអ្នកលក់ និងយកសារធាតុញៀននេះទៅឱ្យអ្នកទិញ ជនជាប់ចោទពិតជាមានការព្រមព្រៀងដោយផ្ទាល់ជាមួយឈ្មោះ **លឹម ឡេងប៊ុនវ៉ា** ក្នុងសកម្មភាពជួញដូរដោយខុសច្បាប់នូវសារធាតុញៀននេះ ។

៩ នៅក្នុងអង្គហេតុទាំងមូលនៃសំណុំរឿង តុលាការពិនិត្យឃើញថា មិនមានភស្តុតាងណាមួយដែលអាចបញ្ជាក់បានថា ឈ្មោះ [redacted] **ផេងហួរសុផារី** បានប្រព្រឹត្តអំពើដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន នោះទេ ។ នៅក្នុងទំនាក់ទំនងនៃការដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀនខាងលើឃើញថា ត្រូវបានធ្វើឡើងតែរវាងឈ្មោះ [redacted] **ឡេងប៊ុនវ៉ា** និងឈ្មោះ [redacted] **ម៉េងគង់** តែប៉ុណ្ណោះ ទាំងអង្គហេតុពាក់ព័ន្ធទៅនឹងការទំនាក់ទំនង និងអង្គហេតុពាក់ព័ន្ធទៅនឹងការដឹកជញ្ជូន ។ បន្ថែមពីលើនេះទៀត តាមការបំភ្លឺរបស់មន្ត្រីនគរបាល

យុត្តិធម៌នាពេលសួរនាការ និងក្នុងរបាយការណ៍សំអេកគក៏បានបង្ហាញផងដែរថា តម្រុយដែលមានចំពោះឈ្មោះ[redacted] **សេងហួរសុផារី** គឺវត្តមានជននេះនៅក្នុងទីតាំងផ្ទះជួលដែលឈ្មោះ[redacted] **ម៉េងគង់** លាក់ទុកនូវសារធាតុញៀនប៉ុណ្ណោះ ។ តាមលទ្ធផលនៃការពិភាក្សាដេញដោល តុលាការពិនិត្យឃើញថា ឈ្មោះ[redacted] **ម៉េងគង់** បន្ទាប់ពីបានទទួលសារធាតុញៀន ជនជាប់ចោទបានយកសារធាតុញៀនទៅលាក់ទុកក្នុងបន្ទប់ជួលតែម្នាក់ឯងប៉ុណ្ណោះ រួចទើបហើយជនជាប់ចោទធ្វើដំណើរទៅទីកន្លែងស្នាក់នៅរបស់ឈ្មោះ[redacted] **សុគន្ធារី** ដើម្បីទទួលឈ្មោះ[redacted] **សេងហួរសុផារី** មកស្នាក់នៅផ្ទះជួលរបស់ខ្លួនវិញ ។ ហេតុដូចនេះ ជនជាប់ចោទឈ្មោះ[redacted] **សេងហួរសុផារី** មិនបានចូលរួមក្នុងសកម្មភាព និងស្ថិតក្នុងស្ថានភាពដែលមិនមានលទ្ធភាពនឹងដឹងថា ឈ្មោះ[redacted] **ម៉េងគង់** បានធ្វើសកម្មភាពល្មើស ហើយបានយកសារធាតុញៀនលាក់ក្នុងផ្ទះជួលនោះទេ ។ ហេតុដូចនេះ តុលាការយល់ឃើញថា មិនមានបន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted] **សេងហួរសុផារី** នោះទេ ។

១០-ជារួមតាមរបាយការណ៍សមត្ថកិច្ច ចម្លើយរបស់ជនជាប់ចោទ ក៏ដូចជាភស្តុតាងដែលមានក្នុងសំណុំរឿងឃើញថា មិនមានភាពគ្រប់គ្រាន់ដើម្បីបញ្ជាក់ថា ជនជាប់ចោទឈ្មោះ[redacted] **សេងហួរសុផារី** បានចូលរួមសកម្មភាព **ដឹកជញ្ជូន និង ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ជាមួយឈ្មោះ[redacted] **ឡេងប៊ុនរ៉ា** និងឈ្មោះ[redacted] **ប៉េងគង់** នោះទេ កាលពីកាលពីវេឡុងខែមិនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២២ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ និងថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ ប្រព្រឹត្តនៅចំណុចបុរីចំការមួងផ្ទះលេខF៣០ ផ្លូវបេតុង សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ និងខេត្តពោធិ៍សាត់ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១១-តាមកំណត់ហេតុនៃការ ត្រួតពិនិត្យជាក់ស្តែងលេខ ០២៩ កណហ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ និងកំណត់ហេតុចាប់យកសម្ភារៈលេខ ០៣៨ កណហ របស់សមត្ថកិច្ចនគរបាលយុត្តិធម៌ នៃមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀនឃើញថា សមត្ថកិច្ចបានចាប់យកអាវុធខ្លីមួយដើមម៉ាក GLock19 ដែលមានលេខ YC20-9356 និងបង់មួយគ្រាប់ចំនួនបីគ្រាប់ ពីឈ្មោះ[redacted] **សុគន្ធារី** ។

១២-ជនជាប់ចោទឈ្មោះ[redacted] **សុគន្ធារី** បានទទួលស្គាល់ថា ជនជាប់ចោទពិតជាបានទទួលកញ្ចប់ខ្មៅបិទជិតពីឈ្មោះ[redacted] **ម៉េងគង់** និងបានយកទៅរក្សាទុកនៅទូរដែករបស់ខ្លួនមែន ។ ប៉ុន្តែជនជាប់ចោទមិនបានដឹងថា នៅក្នុងកញ្ចប់បិទជិតនោះមានកាំភ្លើងនោះទេ ។

១៣-តាមរបាយការណ៍សមត្ថកិច្ចនគរបាលយុត្តិធម៌ ចម្លើយរបស់ជនជាប់ចោទ ក៏ដូចជាភស្តុតាងដែលមានក្នុងសំណុំរឿងឃើញថា មិនមានភាពគ្រប់គ្រាន់ក្នុងការបញ្ជាក់ថា កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ ជនជាប់ចោទឈ្មោះ[redacted] **សុគន្ធារី** ភេទស្រី អាយុ ៣៧ឆ្នាំ បាន **កាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** នោះទេ ។

១៤-តាមលទ្ធផលនៃការពិភាក្សាដេញដោល និងតាមភស្តុតាងនានាដែលប្រមូលបានឃើញថា អាវុធកាំភ្លើងខ្លីម៉ាក G-LOCK ដែលមានលេខ YC20-9356 ចំនួន ០១ ដើម ត្រូវបានរក្សាទុកក្នុងទូរដែកស្ថិតក្នុងស្ថានភាពវេចខ្ចប់ជិត ហើយសូម្បីតែសមត្ថកិច្ចនគរបាលយុត្តិធម៌ក៏បានបញ្ជាក់ផងដែរថា បើពិនិត្យស្ថានភាពខាងក្រៅមិនអាចដឹងថានៅក្នុងកញ្ចប់នោះមានកាំភ្លើងនោះទេ ។ ចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted] **ឡេងប៊ុនរ៉ា** ជនជាប់ចោទឈ្មោះ[redacted] **ម៉េងគង់** ជនជាប់ចោទឈ្មោះ[redacted] **សេងហួរសុផារី** ព្រមទាំងចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted] **សុគន្ធារី** ផ្ទាល់ តាំងពីតំណាក់កាលសមត្ថកិច្ចនគរបាលយុត្តិធម៌រហូតដល់តំណាក់កាលជំនុំជម្រះបានបង្ហាញថា ជនជាប់ចោទឈ្មោះ[redacted] **សុគន្ធារី** មិនបានដឹងថា នៅក្នុងកញ្ចប់ខ្មៅនោះមានកាំភ្លើងនោះទេ ។ កាំភ្លើងដែលរក្សាទុកនៅក្នុងកញ្ចប់ខ្មៅនោះត្រូវបានវេចខ្ចប់ជិត ហើយបានប្រគល់ឱ្យឈ្មោះ[redacted] **សុគន្ធារី** យកទៅរក្សាទុក ហើយនៅពេលដែលសមត្ថកិច្ចឆែកឆេរទីតាំងរកឃើញនូវកាំភ្លើងនេះក៏ស្ថិតក្នុងស្ថានភាពវេចខ្ចប់ជិតដដែល ។



Scanned with CamScanner

១៤-តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី២ ការបញ្ជូនតាមគ្រប់រូបភាពដែលនាំឱ្យមានការផ្លាស់ទី ពីទីកន្លែងមួយទៅទីកន្លែងមួយទៀត ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ឬពីប្រទេសមួយទៅប្រទេសមួយទៀតដោយខុសច្បាប់នូវ សារធាតុញៀនជាអាទិ៍ តាមរយៈការផ្ញើ ការធ្វើចរាចរ ការនាំចូល ឬការនាំចេញ គឺជា **អំពើដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន** ។

**១៥-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ឡេងប៊ុនរ៉ា** និងឈ្មោះ [redacted] **ម៉េងគង់** ដែលបានធ្វើសកម្មភាពផ្លាស់ទីសារធាតុញៀនពីកន្លែងមួយទៅកន្លែងមួយគឺជាបទល្មើស **ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន** តាមមាត្រា ៤០ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៦-តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ការផ្តល់សម្រាប់លក់ ការលក់ ការទិញដើម្បីលក់ ឬដោះដូរ ការដោះដូរដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ។

**១៧-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ឡេងប៊ុនរ៉ា** និងឈ្មោះ [redacted] **ម៉េងគង់** បានដែលបានព្រមព្រៀងដោយផ្ទាល់ជាមួយឈ្មោះ ហ៊ា ធ្វើសកម្មភាពលក់ដោយខុសច្បាប់នូវសារធាតុញៀនគឺជាបទល្មើស **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** តាមមាត្រា ៤០ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៨-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការមានហេតុផលមួយចំនួនដែលនាំឱ្យតុលាការទទួលយក និងបដិសេធទៅលើចំណុចមួយចំនួន ។ ដោយឡែកសេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទដែលស្នើសុំឱ្យតុលាការសម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** និងឈ្មោះ [redacted] **ម៉េងគង់** រួចផុតបទចោទពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** មិនមានមូលដ្ឋានដែលអាចឱ្យតុលាការពិចារណាបានឡើយ ។ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ឡេងហួរសុផារី** និងឈ្មោះ [redacted] **សុគន្ធារី** ដែលបានសន្និដ្ឋានឱ្យជនជាប់ចោទរួចផុតបទចោទមានសំអាងគ្រប់គ្រាន់គប្បីតុលាការពិចារណា ។

១៩-មានពិរុទ្ធគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** ភេទប្រុស អាយុ ៣៥ឆ្នាំ និងឈ្មោះ [redacted] **ម៉េង គង់** ភេទប្រុស អាយុ ៣០ឆ្នាំ ពីបទ **ដឹកជញ្ជូន និង ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចបុរីចិការអូងផ្ទះលេខF៣០ ផ្លូវបេតុង សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ និងខេត្តពោធិ៍សាត់ កាលពីអំឡុងខែមីនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២២ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ និងថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២០-ពុំមានពិរុទ្ធគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **ឡេងហួរសុផារី** ភេទស្រី អាយុ ២០ឆ្នាំ ពីបទ **ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចបុរីចិការអូងផ្ទះលេខF៣០ ផ្លូវបេតុង សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ និងខេត្តពោធិ៍សាត់ កាលពីអំឡុងខែមីនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២២ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ និងថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នោះទេ គប្បីតុលាការសម្រេចឱ្យជនជាប់ចោទរួចផុតបទចោទ ។

២១-ពុំមានពិរុទ្ធគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **សុគន្ធារី** ភេទស្រី អាយុ ៣៧ឆ្នាំ ពីបទ **កាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** ប្រព្រឹត្តនៅចំណុចផ្ទះលេខ៥៩៤ ក្រុមទី១៧ ភូមិព្រែករាំង សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ នោះទេ គប្បីតុលាការសម្រេចឱ្យជនជាប់ចោទរួចផុតពីបទចោទ ។



Scanned with CamScanner

២២-តាមកំណត់ហេតុទទួលវត្ថុតាងចាប់យកលេខ **៥៦៤** រ.ប.ត ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញឃើញថា វត្ថុតាងចាប់យកដែលជាទ្រព្យសម្បត្តិដកហូតពីជនជាប់ចោទឈ្មោះ [redacted] **ម៉េងគង់ រួមមាន៖** ១-ម្សៅម៉ែតពណ៌សចំនួន ៦០ ដុំ (ក្នុង ១ ដុំ ទម្ងន់ ៣៥២,៩១ ក្រាម) ទម្ងន់សរុបចំនួន ២១.១៧៤,៦ ក្រាម ២-ក្រាមពណ៌សថ្លាទម្ងន់ ០,៤៩ ក្រាម ៣-រថយន្តម៉ាក TOYOTA PRUIS ពណ៌ទឹកមាស ពាក់ស្លាកលេខ ភ្នំពេញ 2AX-0331 ចំនួន ០១ (មួយ) គ្រឿង (អ៊ិនប្រក្រតី) ៤-ទូរស័ព្ទម៉ាក OPPO ពណ៌ខៀវ ចំនួន ០១ (មួយ) គ្រឿង (មិនដំណើរការ) និង ៥-ឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន ដកហូតពីឈ្មោះ [redacted] **ម៉េងគង់** និងឈ្មោះ [redacted] **ឆេងហួរសុដារី ចំណែកវត្ថុតាងចាប់យកពីឈ្មោះ** [redacted] **សុគន្ធារី** មាន៖ **១-អាវុធខ្លីម៉ាក G-LOCK ដែលមានលេខ YC20-9356 ចំនួន ០១ ដើម ២-បង់ចំនួន ០១ បង់ ៣-គ្រាប់ចំនួន ០៣ គ្រាប់ និង៤-ទូរស័ព្ទម៉ាក OPPO ពណ៌ស្វាយ (វ៉ែកអេក្រង់) ចំនួន០១គ្រឿង (មិនដំណើរការ)** ។ វត្ថុតាងចាប់យកទាំងនេះជនជាប់ចោទប្រើប្រាស់ជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើស ឬជាផលនៃបទល្មើស គប្បីតុលាការសម្រេចរឹបអូស ។

**២៣**-តាមកំណត់ហេតុទទួលវត្ថុតាងចាប់យកលេខ ៥៦៤ រ.ប.ត ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ឃើញថា វត្ថុតាងចាប់យកដែលជាទ្រព្យសម្បត្តិដកហូតពីជនជាប់ចោទរួមមាន ១.លិខិតឆ្លងដែនលេខ N00773000 របស់ឈ្មោះ [redacted] **សុគន្ធារី** ២.លិខិតឆ្លងដែនដែលលេខ N0674423 របស់ឈ្មោះ [redacted] **សុគន្ធារី** ៣.សៀវភៅស្នាក់នៅរបស់ឈ្មោះ [redacted] **ផាន់ណា** ៤.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ លេខ 010536651 (01) របស់ឈ្មោះ [redacted] **សុគន្ធារី** ៥.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ លេខ 021042981 របស់ឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** (ផុតកម្លង) ៦.ឯកសារពាក់ព័ន្ធមួយចំនួន និងទូរស័ព្ទម៉ាក OPPO ពណ៌ផ្លែមោរ ចំនួន ០១គ្រឿង (មិនដំណើរការ) របស់ឈ្មោះ [redacted] ឆេងហួរសុដារី ។ វត្ថុតាងចាប់យកទាំងនេះមិនមានការពាក់ព័ន្ធទៅនឹងបទល្មើស ហើយជាទ្រព្យសម្បត្តិស្របច្បាប់របស់ជនជាប់ចោទ គប្បីប្រគល់ជូនជនជាប់ចោទវិញ ។

**២៤**-តាមដីកាសម្រេចរឹបអូសវត្ថុតាងលេខ ៣០១៤ "ខ" ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញបានសម្រេចរឹបអូស និងបំផ្លាញចោលនូវវត្ថុតាងជាសារធាតុញៀនរួមមាន៖ ម្សៅម៉ែតពណ៌សចំនួន ៦០ ដុំ (ក្នុង ១ ដុំ ទម្ងន់ ៣៥២,៩១ ក្រាម) ទម្ងន់សរុបចំនួន ២១.១៧៤,៦ ក្រាម និង ក្រាមពណ៌សថ្លាទម្ងន់ ០,៤៩ ក្រាម ហើយពុំមានសំណាកនៅសល់ឡើយ ។

**២៥**-តាមកំណត់ហេតុឆែកឆេរ ត្រួតពិនិត្យដាក់ស្លែងលេខ ០២៥ កណាប ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ និងតាមកំណត់ហេតុបិទផ្ទះ-បិទបន្ទប់ លេខ ០២៨ កណាប ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ ឃើញថា មន្ត្រីនគរបាលយុត្តិធម៌បានឆែកឆេរនៅផ្លូវបេតុង បុរីចំការដូង ផ្ទះលេខF៣០ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ និងចាប់យកសំភារៈវត្ថុតាងរួមមាន ម្សៅស សង្ស័យជាសារធាតុញៀន ចំនួន៦០ដុំរាយជាបន្ទះ ក្រាមសថ្លាសង្ស័យជាសារធាតុញៀនចំនួន ០១កូនកង់ និងឧបករណ៍ប្រើប្រាស់ថ្នាំញៀន ។ ក្រោយពីការឆែកឆេរផ្ទះ/បន្ទប់ខាងលើចប់សព្វគ្រប់ គណកម្មការបានបិទផ្ទះនេះជាបណ្ដោះអាសន្ន ។

**២៦**-ស្របតាមការបញ្ជាក់របស់ម្ចាស់ផ្ទះឈ្មោះ [redacted] **ហួរ** និងឯកសារពាក់ព័ន្ធនានាដែលមាននៅក្នុងសំណុំរឿង តុលាការពិនិត្យឃើញថា អចលនវត្ថុដែលជាកម្មវត្ថុផ្ទះលេខF៣០ ផ្លូវបេតុង ភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ជាទ្រព្យសម្បត្តិរបស់ឈ្មោះ [redacted] **ហួរ** ជាតតិយជន ។ នាពេលបច្ចុប្បន្ន ការជំនុំជម្រះត្រូវបានធ្វើឡើង ពុំមានភាពចាំបាច់ក្នុងការបន្តរក្សាផ្ទះខាងលើដើម្បីជាប្រយោជន៍នៃការស្រាវជ្រាវទៀតទេ គប្បីប្រគល់ជូនម្ចាស់ដើមវិញ ។ ជាងនេះទៀត បើទោះបីជាទីតាំងនេះជាទីតាំងដែលមានរក្សាទុកនូវសារធាតុញៀនក៏ដោយក៏ទីតាំងនេះជាកម្មសិទ្ធិរបស់តតិយជនសុចរិតដែលការរឹបអូសមិនអាចធ្វើឡើងចំពោះតតិយជនក្នុងករណីនេះបានទេ ។



Scanned with CamScanner

**២៧**-តាមកំណត់ហេតុឆែកឆេរ ត្រួតពិនិត្យជាក់ស្តែងលេខ ០២៩ កណប ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ និងតាមកំណត់ហេតុបិទផ្ទះ-បិទបន្ទប់ លេខ ០៣០ កណប ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ ឃើញថា មន្ត្រីនគរបាលយុត្តិធម៌បានឆែកឆេរនៅផ្លូវបេតុង ផ្ទះលេខ៥៩៤ ក្រុមទី១៧ ភូមិព្រែកភាំង សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ និងចាប់យកសម្ភារៈវត្ថុតាងរួមមាន អាវុធខ្លីមួយគ្រឿងម៉ាក G-LOCK19 លិខិតឆ្លងដែនឈ្មោះ [redacted] សុគន្ធារី ភេទស្រី ចំនួន២ច្បាប់ សៀវភៅស្នាក់នៅឈ្មោះ លឹម ផាន់ណា ភេទប្រុស ចំនួន០១ច្បាប់ អត្តសញ្ញាណ ប័ណ្ណសញ្ជាតិខ្មែរ ចំនួន០១ ឯកសារពាក់ព័ន្ធមួយចំនួន ។ ក្រោយពីការឆែកឆេរផ្ទះ/បន្ទប់ខាងលើចប់សព្វគ្រប់ គណកម្មការបានបិទផ្ទះនេះជាបណ្តោះអាសន្ន ។

**២៨**-ស្របតាមការបញ្ជាក់របស់ម្ចាស់ផ្ទះឈ្មោះ [redacted] **សេង** និងឯកសារពាក់ព័ន្ធនានាដែលមាននៅក្នុងសំណុំរឿង តុលាការយល់ឃើញថា អចលនវត្ថុដែលជាកម្មវត្ថុផ្ទះល្វែង៥៣ ផ្លូវលំ ភូមិព្រែកភាំង១ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល ជាទ្រព្យសម្បត្តិរបស់ឈ្មោះ [redacted] **សេង** ។ នាពេលបច្ចុប្បន្ន ការជំនុំជម្រះត្រូវបានធ្វើឡើងពុំមានភាពចាំបាច់ក្នុងការបន្តរក្សាផ្ទះខាងលើដើម្បីជាប្រយោជន៍នៃការស្រាវជ្រាវទៀតទេ គប្បីប្រគល់ជូនម្ចាស់ដើមវិញ ។

<u>**ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី**</u>

១-ឱ្យ ពេញ្ញា: [redacted] **ហេងហួរសុផារី** ភេទស្រី អាយុ ២០ឆ្នាំ ដែលមានអត្តសញ្ញាណខាងលើ រួចផុតបទចោទពីបទ **ជួញដូរ និងផ្តល់ផ្តួរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចបុរីចំការដូងផ្ទះលេខ៥-៣០ ផ្លូវបេតុង សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ និងខេត្តពោធិ៍សាត់ កាលពីអំឡុងខែមីនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២២ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ និងថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-ឱ្យ ពេញ្ញា: [redacted] **សុគន្ធារី** ភេទស្រី អាយុ ៣៧ឆ្នាំ ដែលមានអត្តសញ្ញាណខាងលើ **រួចផុតបទចោទ** ពីបទ **កាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** ប្រព្រឹត្តនៅចំណុចផ្ទះលេខ៥៩៤ ក្រុមទី១៧ ភូមិព្រែកភាំង សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ ។

៣-ផ្តន្ទាទោស ឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** ភេទប្រុស អាយុ ៣៥ឆ្នាំ និងឈ្មោះ [redacted] **ម៉េងគង់** ភេទប្រុស អាយុ ៣០ឆ្នាំ ដែលមានអត្តសញ្ញាណខាងលើ ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗ **អស់មួយជីវិត និង ពិន័យជាប្រាក់ចំនួន ៤០.០០០ ០០០ (សែសិបលាន) រៀល** ពីបទ **ជួញដូរ និង ផ្តល់ផ្តួរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចបុរីចំការដូងផ្ទះលេខ៥-៣០ ផ្លូវបេតុង សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ និងខេត្តពោធិ៍សាត់ កាលពីអំឡុងខែមីនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២២ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ និងថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**៤-រឹបអូសវត្ថុចាប់យក និងទ្រព្យសម្បត្តិដូចខាងក្រោម៖**

-រថយន្តម៉ាក TOYOTA PRUIS ពណ៌ទឹកមាស ពាក់ស្លាកលេខ ភ្នំពេញ 2AX-0331 ចំនួន ០១ (មួយ) គ្រឿង។

-ទូរស័ព្ទម៉ាក OPPO ពណ៌ខៀវ ចំនួន ០១ (មួយ) គ្រឿង ។

-ឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន ។



Scanned with CamScanner

-អាវុធខ្លីម៉ាក G-LOCK ដែលមានលេខ YC20-9356 ចំនួន ០១ (មួយ) ដើម ។

-បង់ចំនួន ០១ (មួយ) បង់ ។

-គ្រាប់ចំនួន ០៣ (បី) គ្រាប់ ។

-ទូរស័ព្ទម៉ាក OPPO ពណ៌ស្វាយ ចំនួន ០១ (មួយ) គ្រឿង ។

៥-ប្រគល់ទៅឱ្យម្ចាស់ដើមវិញនូវវត្ថុចាប់យក៖

-លិខិតឆ្លងដែនលេខ N00773000 របស់ឈ្មោះ [redacted] **សុគន្ធារី** ។

-លិខិតឆ្លងដែនដែនលេខ N0674423 របស់ឈ្មោះ [redacted] **សុគន្ធារី** ។

-សៀវភៅស្នាក់នៅរបស់ឈ្មោះ [redacted] **ផាន់ណា** ។

-អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរលេខ លេខ 010536651 (01) របស់ឈ្មោះ [redacted] **សុគន្ធារី** ។

-អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរលេខ លេខ 021042981 របស់ឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** (ចម្លង) ។

-ឯកសារពាក់ព័ន្ធមួយចំនួន ។

-ទូរស័ព្ទម៉ាក OPPO ពណ៌ផ្ទៃមេឃចំនួន ០១ (មួយ) គ្រឿង ។

៦-ប្រគល់ផ្ទះលេខ F៣០ ផ្លូវបេតុង ភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ទៅឱ្យម្ចាស់ដើម ឈ្មោះ [redacted] **ហួរ** វិញ ។

៧-ប្រគល់ផ្ទះល្វែង B៣ (៥៩៤) ផ្លូវលំ ភូមិព្រែករាំង១ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្ដាល ទៅឱ្យម្ចាស់ដើមឈ្មោះ [redacted] **សេង** វិញ ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ម៉េង គង់** ឈ្មោះ [redacted] **គេងហួរសុផារី** និងឈ្មោះ [redacted] **សុគន្ធារី** ចាត់ទុកចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ឡេងប៊ុនរ៉ា** ប្រកាសជាសាធារណៈថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣ ទុកសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| --- | --- | --- |

ហត្ថលេខា និងត្រា [redacted]

**បានឃើញ**

ថ្ងៃចន្ទ ១កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃចន្ទ ១កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner